# ក្រុមទស្សនវិទូនិយមការសិក្សាស្រាវជ្រាវដើម្បីបង្កើតទ្រឹស្តីថ្មី ( Constructivist )

ដោយបណ្ឌិត វង់ សំអូន
ជំនួយការឧទ្ទកាល័យរាជបណ្ឌិត្យសភាកម្ពុជា

ក្រុមទស្សនវិទូបានប្រើប្រាស់គោលវិធីសិក្សាស្រាវជ្រាវផ្សេងៗគ្នា ដើម្បីឈានទៅបង្កើតចំណេះដឹង ឬរបកគំហើញថ្មីៗ ដោយអាស្រ័យលើបញ្ហាកំពុងសិក្សាស្រាវជ្រាវទាំងនោះ។ ក្រុមទស្សនវិទូដែលនិយមការសិក្សាស្រាវជ្រាវដើម្បីបង្កើតទ្រឹស្តីថ្មីៗ ( Theory generation ) បានផ្តោតយ៉ាងសំខាន់លើការប្រើប្រាស់ ***គោលវិធីសិក្សាស្រាវជ្រាវតាមបែបគុណវិស័យតែប៉ុណ្ណោះ*** ដោយបានសិក្សាលើបាតុភូត ព្រឹត្តិការណ៍ ឬបញ្ហាទាំងឡាយដែលបានកើតមានឡើង កំពុងកើតឡើង ឬនឹងកើតឡើងនាពេលណាមួយក្នុងអនាគត។ ទស្សនវិទូក្រុមនេះបានធ្វើការសិក្សាស្រាវជ្រាវយ៉ាងល្អិតល្អន់តាមរយៈការប្រមូលទិន្នន័យពី***ក្រុមគោលដៅមួយចំនួនតូចតែប៉ុណ្ណោះ***ដែលជាក្រុមគោលដៅយល់ដឹងពីបញ្ហាកំពុងសិក្សាស្រាវជ្រាវបានយ៉ាងស៊ីជម្រៅ។ ការប្រមូលទិន្នន័យត្រូវបានធ្វើឡើងតាមរយៈការសម្ភាសន៍ ការសង្កេតយ៉ាងល្អិតល្អន់លើបញ្ហា ឬបាតុភូតកំពុងសិក្សាស្រាវជ្រាវ ការវិភាគឯកសារផ្សេងៗ ការវិភាគខ្សែអាត់សម្លេង ការវិភាគវីដេអូ ការវិភាគរូបថត ឬការវិភាគលើលទ្ធផលនៃកំណាយផ្សេងៗជាដើម។ល។

ឧទាហរណ៍ ក្នុងការសិក្សាស្វែងយល់ពីការលិចកប៉ាល់ទីតានិច (Titanic)។ តាមធម្មជាតិរបស់បញ្ហានេះ បានបង្ហាញថាការសិក្សាស្រាវជ្រាវនេះ គឺត្រូវបានធ្វើឡើងដោយប្រើប្រាស់គោលវិធីសិក្សាស្រាវជ្រាវតាមបែបបគុណវិស័យពីព្រោះបញ្ហានេះមិនបានផ្តោតលើកម្មវត្ថុវិស័យ ឬការផ្ទៀងផ្ទាត់ទ្រឹស្តីនោះទេ ប៉ុន្តែវាបានផ្តោតយ៉ាងសំខាន់លើប្រធានវិស័យ។ ការប្រមូលទិន្នន័យត្រូវបានធ្វើឡើងតាមរយៈការវិភាគ ការសម្ភាសន៍ ឬការសង្កេតអ្វីមួយដោយផ្ទាល់ ឬមិនផ្ទាល់ដើម្បីទទួលបានដំណោះស្រាយ ចម្លើយ ការយល់ឃើញថ្មី ឬការបង្កើតទ្រឹស្តីថ្មី។ នេះមានន័យថា អ្នកសិក្សាស្រាវជ្រាវអាចចុះទៅពិនិត្យកប៉ាលទីតានិចដែលបានលិចនៅក្នុងបាតសមុទ្រដោយផ្ទាល់ ចុះថតជារូបភាព ជាវីដេអូ យករូបភាព ឬយកវីដេអូដែលមានស្រាប់ រួចហើយធ្វើការវិភាគទិន្នន័យទាំងនោះទៅតាមខ្លឹមសារដែលចង់ស្វែងយល់ និងបន្ទាប់មកធ្វើសេចក្តីសន្និដ្ឋានដើម្បីបង្កើតបានជាចំណេះដឹងថ្មី ឬទ្រឹស្តីថ្មីចេញពីការវិភាគនោះ។ នៅក្នុងការសិក្សាស្រាវជ្រាវបែបនេះគឺបានចាត់ចូលទៅក្នុងក្រុមទស្សនវិទូនិយមការសិក្សាស្រាវជ្រាវដើម្បីបង្កើតទ្រឹស្តីថ្មី តាមរយៈការប្រើប្រាស់គោលវិធីសិក្សាស្រាវជ្រាវតាមបែបគុណវិស័យ។

ម៉្យាងវិញទៀត ទស្សនវិទូក្រុមនេះក៏បានផ្តោតយ៉ាងសំខាន់លើគោលបំណងក្នុងការសិក្សាស្វែងយល់ឱ្យបានស៊ីជម្រៅ ចេញពីការយល់ឃើញ បទពិសោធន៍ វប្បធម៌ ទំនៀមទំលាប់ប្រពៃណី ពិធីផ្សេងៗ ជំនឿ សាសនា ការគោរពប្រតិបត្តិ ភាសា ដើមកំណើត បាតុភូតធម្មជាតិ ឬបាតុភូតសង្គម។ល។ ដែលបុគ្គលម្នាក់ៗបានឆ្លងកាត់ បានជួបប្រទះ ឬបាននៅក្នុងហេតុការណ៍នោះ។ ទស្សនវិទូក្រុមនេះយល់ថា

បុគ្គលម្នាក់ៗអាចមានការយល់ដឹងខុសគ្នា ប្រហាក់ប្រែលគ្នា ឬដូចគ្នាលើព្រឹត្តិការណ៍ ឬហេតុការណ៍អ្វីមួយ ដែលពួកគេបានជួបប្រទះដោយអាស្រ័យលើសម័យកាល ទីកន្លែង ឬស្ថានភាពដែលពួកគេបានឆ្លងកាត់។

ឧទាហរណ៍ ក្នុងការសិក្សាស្រាវជ្រាវដើម្បីធ្វើការស្វែងយល់ពីការយល់ឃើញរបស់ប្រជាពលរដ្ឋលើរបបប្រល័យពូជសាសន៍។ តាមធម្មជាតិនៃបញ្ហានេះបានទាមទារឱ្យអ្នកសិក្សាស្រាវជ្រាវប្រើប្រាស់គោលវិធីសិក្សាស្រាវជ្រាវតាមបែបគុណវិស័យពីព្រោះវាបានផ្តោតសំខាន់លើការបង្កើតចំណេះដឹងថ្មី ឬទ្រឹស្តីថ្មីចេញពីប្រធានវិស័យតាមរយៈការសម្ភាសន៍ ដើម្បីធ្វើការសិក្សាស្វែងយល់ពីការយល់ឃើញរបស់ក្រុមប្រជាពលរដ្ឋណាមួយដែលជាក្រុមគោលដៅបានឆ្លងកាត់ ជួបប្រទះ និងបានយល់ដឹងស៊ីជម្រៅលើព្រឹត្តិការណ៍នោះ ហើយពួកគេអាចរៀបរាប់ពីព្រឹត្តិការណ៍ ឬហេតុការណ៍ទាំងនោះបានយ៉ាងល្អិតល្អន់។ ការសិក្សាស្រាវជ្រាវបែបនេះគឺបានចាត់ចូលទៅក្នុងក្រុមទស្សនវិទូនិយមការសិក្សាស្រាវជ្រាវ ដើម្បីបង្កើតទ្រឹស្តីថ្មីតាមរយៈការប្រើប្រាស់គោលវិធីសិក្សាស្រាវជ្រាវតាមបែបគុណវិស័យ។

លើសពីនេះទៀត ទស្សនវិទូក្រុមនេះក៏បានបញ្ជាក់ផងដែរថា នៅក្នុងសង្គមនីមួយៗតែងតែមានវប្បធម៌ អរិយធម៌ ទំនៀមទំលាប់ ជំនឿ ភាសា ឬការប្រតិបត្តិខុសៗគ្នា។ល។ សង្គមខ្លះបានគោរពសាសនាព្រះពុទ្ធដោយផ្តោតសំខាន់លើទស្សនកម្មផល រីឯសង្គមខ្លះទៀតកាន់សាសនាអ៊ីស្លាមដោយចាត់ទុកថាសត្វឆ្កែប្រៀបដូចជាឪពុក ចំណែកសត្វជ្រូកប្រៀបដូចជាម្តាយ ហើយនៅក្នុងសង្គមនោះក៏មានការប្រតិបត្តិ ឬការយល់ឃើញខុសៗគ្នាពីគ្រួសារមួយទៅគ្រួសារមួយ ពីភូមិមួយទៅភូមិមួយ ឬពីតំបន់មួយទៅតំបន់មួយផងដែរ។ ដូច្នេះគេអាចនិយាយបានថា នៅក្នុងសង្គមនីមួយៗមានរចនាសម្ព័ន្ធនៃការកកើត ឬការប្រតិបត្តិមានលក្ខណៈស្មុគស្មាញដែលទាមទារឱ្យយើងធ្វើការសិក្សាស្រាវជ្រាវ ដើម្បីស្វែងយល់ពីភាពស្មុគស្មាញទាំងនោះ។ ក្នុងន័យនេះ ក្រុមទស្សនវិទូនិយមការសិក្សាស្រាវជ្រាវដើម្បីបង្កើតទ្រឹស្តីថ្មី បានយកចំណុចនេះ (ការសិក្សាស្វែងយល់ពីភាពស្មុគស្មាញរបស់សង្គមចេញពីបុគ្គលដែលបានរស់នៅក្នុងសង្គម ឬបរិបទនោះ) ដើម្បីបង្កើតបានជាចំណេះដឹងថ្មី ឬទ្រឹស្តីថ្មីសម្រាប់មនុស្សទូទៅក្នុងសង្គមបច្ចុប្បន្ន ឬអនាគតបានយល់ដឹង។

ឧទាហរណ៍ ការសិក្សាស្រាវជ្រាវរុករកពីដើមកំណើតនៃរបាំក្ងោក។ តាមធម្មជាតិនៃបញ្ហានេះបានទាមទារឱ្យអ្នកសិក្សាស្រាវជ្រាវធ្វើការសិក្សាស្រាវជ្រាវ ដោយប្រើប្រាស់គោលវិធីសិក្សាស្រាវជ្រាវតាមបែបគុណវិស័យពីព្រោះវាជាការសិក្សាស្វែងយល់ពីគំនិតរបស់បុគ្គលម្នាក់ៗដែលបានដឹង ឬឆ្លងកាត់រឿងរ៉ាវទាក់ទងនឹងបញ្ហានេះ ឬការវិភាគឯកសារផ្សេងៗដែលទាក់ទងនឹងបញ្ហានេះ។ ផ្អែកលើបញ្ហានេះ អ្នកសិក្សាស្រាវជ្រាវអាចធ្វើការប្រមូលទិន្នន័យដោយប្រើវិធីណាមួយដូចជា៖ ការសម្ភាសន៍បុគ្គលដែលបានដឹងរឿងនេះ(ការយល់ឃើញរបស់បុគ្គលម្នាក់អាចមានភាពខុសគ្នា ស្រដៀងគ្នា ឬដូចគ្នាលើបញ្ហានេះអាស្រ័យទៅតាមបទពិសោធន៍របស់ពួកគេម្នាក់ៗដែលបានដឹង ជួបប្រទះ បានឃើញហេតុការណ៍) ការវិភាគឯកសារ ការវិភាគរូបថត ឬការវិភាគវីដេអូដែលទាក់ទងនឹងរឿងនេះ។ល។ បន្ទាប់ពីការប្រមូលទិន្នន័យរួចហើយ អ្នក

សិក្សាស្រាវជ្រាវអាចធ្វើការវិភាគ សំយោគ និងសន្និដ្ឋានតាមជាតុគោលដែលចង់ស្វែងយល់ ហើយទាញបានជាទ្រឹស្តីថ្មី ចំណេះដឹងថ្មី ឬរបកគំហើញពីការសិក្សាស្រាវជ្រាវនេះ។ ការសិក្សាស្រាវជ្រាវបែបនេះគឺបានចាត់ចូលទៅក្នុងក្រុមទស្សនវិទូនិយមការសិក្សាស្រាវជ្រាវ ដើម្បីបង្កើតទ្រឹស្តីថ្មីតាមរយៈការប្រើប្រាស់គោលវិធីសិក្សាស្រាវជ្រាវតាមបែបគុណវិស័យ។

ទស្សនវិទូក្រុមនេះក៏បានលើកឡើងផងដែរថា នៅក្នុងដំណើរការប្រមូលទិន្នន័យនៃការសិក្សាស្រាវជ្រាវដើម្បីបង្កើតទ្រឹស្តីថ្មី ទាមទារឱ្យអ្នកសិក្សាស្រាវជ្រាវប្រើប្រាស់ប្រភេទសំណួរបើក (ហេតុអ្វី...តាមរបៀបណា...យ៉ាងដូចម្តេច......មានអ្វីកើតឡើង......កើតឡើងនៅពេលណា....កើតឡើងនៅទីកន្លែងណា.........មានប្រសិទ្ធភាព ឬផលប៉ះពាល់យ៉ាងដូចម្តេច......)ដែលអាចធ្វើឱ្យក្រុមគោលដៅងាយយល់ និងមានលទ្ធភាពផ្តល់ចម្លើយបានច្រើនដែលអាចធ្វើទៅបានដោយសារក្រុមគោលដៅគឺជាបុគ្គលដ៏សំខាន់នៅក្នុងការផ្តល់ចម្លើយ (ក្នុងករណីការប្រមូលទិន្នន័យត្រូវបានធ្វើឡើងតាមរយៈវិធីសម្ភាសន៍)។ ក្នុងករណីក្រុមគោលដៅមិនយល់ច្បាស់ពីសំណួរ ឬសំណួរដែលបានសួរមិនមានភាពច្បាស់លាស់ ដូច្នេះពួកគេមិនអាចផ្តល់ចម្លើយបានឡើយ។ *ការប្រើប្រាស់សំណួរបើក និងមានភាពងាយស្រួលយល់បានច្រើនកាលណាក្រុមគោលដៅក៏អាចផ្តល់ចម្លើយបានច្រើនទៅតាមនោះដែរ*។ រាល់ចម្លើយដែលទទួលបានពីក្រុមគោដៅទាំងអស់ត្រូវបានអ្នកសិក្សាស្រាវជ្រាវវិភាគជារួម (ទំនាក់ទំនងគំនិតរវាងក្រុមគោលដៅលើបញ្ហាដែលកំពុងសិក្សាស្រាវជ្រាវ) មិនមែនវិភាគចម្លើយជាលក្ខណៈបុគ្គលម្នាក់ៗនោះទេ។

ឧទាហរណ៍ ក្នុងការសិក្សាស្រាវជ្រាវដើម្បីឆ្លុះបញ្ចាំងពីការការយល់ឃើញរបស់គ្រូបង្រៀនលើការសរសេរភាសាខ្មែររបស់សិស្សវិទ្យាល័យនាពេលបច្ចុប្បន្ន។ យោងតាមធម្មជាតិនៃបញ្ហាបានទាមទារឱ្យអ្នកសិក្សាស្រាវជ្រាវប្រើប្រាស់គោលវិធីសិក្សាស្រាវជ្រាវតាមបែបគុណវិស័យ ពីព្រោះវាបានផ្តោតយ៉ាងសំខាន់លើប្រធានវិស័យ (ចម្លើយកើតចេញពីការយល់ឃើញរបស់ក្រុមគោលដៅម្នាក់ៗ)។ អ្នកសិក្សាស្រាវជ្រាវប្រើប្រាស់សំណួរបើកនៅក្នុងការប្រមូលទិន្នន័យពីក្រុមគោលដៅដែលជាគ្រូបង្រៀន។ សំណួរទាំងនោះត្រូវមានលក្ខណៈទូលំទូលាយ និងមានភាពងាយស្រួលយល់ដូចជា៖ តើលោកគ្រូ/អ្នកគ្រូមានការយល់ឃើញយ៉ាងណាដែរចំពោះការសរសេរភាសាខ្មែរនាពេលបច្ចុប្បន្នរបស់សិស្សវិទ្យាល័យ?តើមូលហេតុចាំបាច់អ្វីខ្លះដែលបានជំរុញ ឬជះឥទ្ធិពលការសរសេរភាសាខ្មែររបស់សិស្សវិទ្យាល័យនាពេលបច្ចុប្បន្ន? តើបញ្ហានៃការសរសេរខ្មែរនាពេលបច្ចុប្បន្នរបស់សិស្សវិទ្យាល័យគួរដោះស្រាយតាមរបៀបណា?.......

**តារាងទី១៖ ធាតុគោលក្នុងទស្សនិយមនៃការសិក្សាស្រាវជ្រាវដើម្បីបង្កើតទ្រឹស្តីថ្មី**




## ឯកសារយោង


Babbie, E. (1995). The practice of social research (7th Ed.). Wadsworth publishing, California, USA

Creswell, W.J., & Creswell, D.J. (2018). Research Design: Qualitative, quantitative, and mixed methods approach. (5th Ed.). SAGE publication

Cronk, C.B. (2008). How to use SPSS: A step-by-step guide to analysis and interpretation. (5th Ed.). Pyrezak publishing, California, USA

Kerlinger, N.F. & Lee, B.H. (2000). Foundation of behavioral research (4th Ed.). Thomson learning, USA